# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

---

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
### ការសិក្សាស្រាវជ្រាវទៅលើអ្នកចេញទៅបោះឆ្នោត បញ្ជីបោះឆ្នោត លទ្ធផលនៃការបោះឆ្នោតនៅតាមការិយាល័យ និងគុណភាពនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត

ភ្នំពេញ,ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៣

បន្ទប់ស្ថានការណ៍ថ្ងៃបោះឆ្នោត មានគម្រោងសិក្សាស្រាវជ្រាវអំពីបញ្ហាមួយចំនួនទាក់ទងទៅនឹងអ្នកចេញទៅបោះឆ្នោត បញ្ជីបោះឆ្នោត លទ្ធផលនៃការបោះឆ្នោតនៅតាមការិយាល័យ ព្រមទាំងគុណភាពនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត។

យោងតាមលិខិតលេខៈ ១៦៩/១៣ គ.ប.ស.យ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៣ ខុមហ្វ្រែលតាងនាមឲ្យបន្ទប់ស្ថានការណ៍នៃអង្គការសមាគមក្រៅរដ្ឋាភិបាល បានស្នើសុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងការផ្តល់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់១១០២)ពីក្នុងកញ្ចប់ សុវត្ថិភាព "ក" និងថតចំលង ឬថតដោយម៉ាស៊ីនថតរូបនូវគល់បញ្ជីលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោតនៅក្នុងខេត្តកំពង់ចាម ខេត្តកណ្តាល ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តព្រៃវែង និងរាជធានីភ្នំពេញ។

បន្ទប់ស្ថានការណ៍ នឹងធ្វើការស្រាវជ្រាវដោយផ្អែកលើឯកសារដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)ផ្តល់ឲ្យតែប៉ុណ្ណោះ។

***ព័ត៌មានបន្ថែមសូមទាក់ទង៖***

កញ្ញា គង់ រ៉ាវីន អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ០១២ ៦៥ ៤៩ ៥០

COMFREL, ADHOC, NICFEC, YRDP, CCIM, CCHR, CHRAC, NGO FORUM, API, CCC, CDP, CLEC, CPWP, PDP-CENTER, LICADHO, DHRAC, GAD/C, LWD, CISA, KYA, KID, DPA, KYSD, MVI, ICSO, TI/C, SILAKA, STAR KAMPUCHEA, HR VIGILANCE, VBNK, WMC, YCC, HRTF, CPN, IDEA, VSG, CCSP, KHARAM , FACT, MLOP BAITONG.